# ស្តេចអ៊ីស្រាអែលត្រូវចុះចូល

ការប្រកាសព្រះគ្រីស្ទពីគម្ពីរសញ្ញាចាស់ ចោទិយកថា ១៧:១៤-២០

អ្នកនិពន្ធ៖ រុហ្វ លេភិឡារ

## កាលៈទេសៈប្រវត្តិសាស្ត្រ

ជនជាតិអ៊ីស្រាអែលបានបញ្ចប់ការធ្វើដំណើររបស់ពួកគេចេញពីអេស៊ីព្ទ ហើយការវង្វេងនៅក្នុងទីរហោស្ថានរយៈពេល៤០ឆ្នាំក៏បានបញ្ចប់ដែរ។ ពួកគេស្ថិតនៅភាគខាងកើតយ័រដាន់ កំពុងត្រៀមខ្លួនជាស្រេច ដើម្បីចូលទៅក្នុងទឹកដីសន្យា។ កណ្ឌចោទិយកថាកត់ត្រាអំពីសេចក្តីអធិប្បាយបីរបស់ម៉ូសេទៅកាន់បណ្តាជនអ៊ីស្រាអែល ដើម្បីលើកទឹកចិត្តពួកគេអោយកាន់តាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់។

## អត្ថបទសារ

អ៊ីស្រាអែលមិនទាន់មានស្តេចជាមនុស្សនៅឡើយទេ នៅពេលម៉ូសេថ្លែងព្រះបន្ទូលនេះដល់ពួកគេ ប៉ុន្តែព្រះជាម្ចាស់ជាស្តេចសម្រាប់ពួកគេស្រាប់ទៅហើយ (ចោទិយកថា ៣៣:៥)។ ដូច្នេះ នៅពេលពួកគេតាំងស្តេចឡើង នោះជាការផ្លាស់ប្តូរយ៉ាងសំខាន់។ ព្រះជាម្ចាស់ទ្រង់ជាអ្នកគ្រប់គ្រងរួចទៅហើយ ដូច្នេះនឹងទៅជាយ៉ាងណា បើសិនគេតាំងស្តេចជាមនុស្សឲ្យគ្រប់គ្រងលើពួកគេដែរនោះ? អត្ថបទនេះជួយផ្តល់ចម្លើយសំរាប់សំណួរនេះ។ ស្តេច ដែលពួកគេតាំងឡើងអោយគ្រប់គ្រងលើគេនោះ ត្រូវតែចុះចូលចំពោះព្រះជាម្ចាស់។ នៅពេលណាស្តេចចុះចូលចំពោះព្រះបន្ទូលរបស់ព្រះ នោះព្រះជាម្ចាស់ទ្រង់នៅតែគ្រប់គ្រងលើទាំងអស់។

## ទំនាក់ទំនងភ្ជាប់ទៅនឹងអត្ថបទក្រោយមកទៀតក្នុងព្រះគម្ពីរសញ្ញាចាស់

បើសិនយើងដឹងពីរឿងស្តេចសាឡូម៉ូន នោះអត្ថបទនេះរំលឹកយើងយ៉ាងច្បាស់អំពីទ្រង់។ ទ្រង់បានចាប់ផ្តើមល្អ ប៉ុន្តែបានបរាជ័យក្នុងការគោរពតាមបង្គាប់នេះ។ មនុស្សប្រែប្រួលនៅពេលគេមានអំណាច រួមទាំងស្តេចផងដែរ ដូច្នេះស្តេចសាឡូម៉ូនមិនមែនជាស្តេច ដែលអ៊ីស្រាអែលរង់ចាំ ដើម្បីមកបំពេញការទទួលខុសត្រូវជាស្តេច ដែលបានចែងទុកនៅក្នុងអត្ថបទនេះឡើយ។

ពួកគេត្រូវរង់ចាំបុត្រាស្តេចដាវីឌក្រោយមកទៀតសំរាប់តួនាទីនេះ។

## ទំនាក់ទំនងភ្ជាប់ទៅនឹងព្រះគម្ពីរសញ្ញាថ្មី

នៅពេលព្រះយេស៊ូវយាងមក ទ្រង់បានប្រកាសថា ទ្រង់នាំព្រះរាជ្យរបស់ព្រះជាម្ចាស់មកដល់ ហើយទ្រង់គឺជាស្តេច ដែលពួកគេបានរង់ចាំនោះហើយ។ ក្នុងឋានៈជាស្តេចអ៊ីស្រាអែលពិតប្រាកដ ទ្រង់ស្តាប់បង្គាប់ ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌គ្រប់ទាំងអស់ ដូច្នេះហើយព្រះយេស៊ូវមានសិទ្ធិពេញលេញក្នុងការធ្វើជាស្តេច។

នេះជាសារចេញពីភីលីព ២:៥-១១ ព្រោះទ្រង់ស្តាប់បង្គាប់រហូតដល់ទីមរណៈ បានជាទ្រង់គ្រប់គ្រងដូចជាព្រះអម្ចាស់។

ទ្រង់ស្គាល់គ្រប់បទគម្ពីរ និងប្រតិបត្តិតាមបានឥតខ្ចោះ (លូកា ២:៥២; ហេព្រើរ ៤:១៥) ហេតុនោះ ព្រះយេស៊ូវ (និងអស់អ្នកទុកចិត្តលើទ្រង់) បានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ (ហេព្រើរ១២:១-៥)។ ប៉ុន្តែ ទ្រង់មិនគ្រាន់តែស្តេចអ៊ីស្រាអែលទេ គឺទ្រង់ក៏ជាស្តេចនិងអម្ចាស់លើទាំងអស់ផងដែរ (វិវរណៈ ១៧:១៤; ១៩:១៦)។

## សារអធិប្បាយ

ប្រាកដណាស់ ស្តេចជាប្រធានបទសំខាន់នៅក្នុងអត្ថបទនេះ។ យើងអាចភ្ជាប់ទៅបទពិសោធន៍របស់មនុស្ស ដោយនិយាយពីប្រភេទស្តេច ដែលមនុស្សចង់បាន។ មនុស្សនឹងចង់បានស្តេចល្អ មិនមែនជាស្តេចគិតតែបង្កើនទ្រព្យសម្បត្តិដោយពុករលួយនោះឡើយ។ ទោះបីជាយ៉ាងណា នេះគ្រាន់តែគំនិតសាមញ្ញ ទាក់ទងនឹងបទពិសោធន៍របស់មនុស្សនៅពេលបច្ចុប្បន្នតែប៉ុណ្ណោះ។

នៅក្នុងប្រទេសយើងនាពេលបច្ចុប្បន្ន យើងត្រូវតែប្រុងប្រយ័ត្ន មិនត្រូវប្រើអត្ថបទនេះនិយាយពីប្រភេទស្តេចដែលយើងចង់បាននោះទេ។ អត្ថបទនេះមិននិយាយពីស្តេចនៃជនជាតិទូទៅទេ ប៉ុន្តែនិយាយជាពិសេសពីស្តេចអ៊ីស្រាអែល។ ការនិយាយពីស្តេចអ៊ីស្រាអែលគឺជាការនិយាយពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងចុងក្រោយបំផុតនិយាយពីព្រះយេស៊ូវ ដែលជាអង្គយាងមកបំពេញទំនួលខុសត្រូវក្នុងការធ្វើជាស្តេចអ៊ីស្រាអែល។ ដូច្នេះ សារអធិប្បាយ (ត្រូវតែជាសារដែលមកពីអត្ថបទ និងមានការពិចារណាវិវឌ្ឍន៍ឆ្ពោះទៅដល់ព្រះគម្ពីរសញ្ញាថ្មី) គឺថា *ព្រះយេស៊ូវជាស្តេច ដែលព្រះជាម្ចាស់តាំងឡើង អ្នកដែលចុះចូលចំពោះព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ និងមានសិទ្ធិគ្រប់គ្រងអស់កល្បជានិច្ច។*

រួមទាំងការអនុវត្តន៍៖

១. យើងត្រូវទទួលព្រះយេស៊ូវជាស្តេច ព្រះអង្គសង្គ្រោះ ចុះចូលចំពោះទ្រង់ និងសារភាពថា ទ្រង់ជាព្រះអម្ចាស់ (ភីលីព ២:៥-១១)។

២. អរព្រះគុណដល់ព្រះយេស៊ូវ និងសរសើរទ្រង់ ដែលព្រះអង្គស្តាប់បង្គាប់តាមព្រះវរបិតាបានយ៉ាងឥតខ្ចោះ ហើយទ្រង់គ្រប់គ្រងយើងនាពេលបច្ចុប្បន្ននេះ។